00772899

E162

# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 31 / 01 / 2012
ម៉ោង (Time/Heure): 16:35
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

## អនុស្សរណៈ អង្គជំនុំជម្រះសាលាដំបូង

កាលបរិច្ឆេទ: ថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១២

**ជូនចំពោះ:** ភាគីទាំងអស់នៃសំណុំរឿង ០០២

**ពី:** **លោកចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង**

**ចម្លងជូន:** លោក/លោកស្រីចៅក្រមទាំងអស់នៃអង្គជំនុំជម្រះសាលាដំបូង និងមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង

**កម្មវត្ថុ:** ចម្លើយតបរបស់អង្គជំនុំជម្រះសាលាដំបូងទៅនឹងផ្នែកខ្លះនៃឯកសារ **E114, E114/1, E131/1/9, E131/6, E136 និង E158**

នៅថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១២ អង្គជំនុំជម្រះសាលាដំបូង បានចេញសេចក្តីសម្រេចផ្ទាល់មាត់ដូចខាងក្រោម៖

១. ក្នុងអំឡុងសវនាការនាសប្តាហ៍កន្លងទៅនេះ ភាគីបានលើកឡើងសំណួរពាក់ព័ន្ធនឹងការអនុវត្តឱ្យបានសមស្របតាមវិធាន៨៧ នៃវិធានផ្ទៃក្នុង។ អង្គជំនុំជម្រះសាលាដំបូងសូមផ្តល់គោលការណ៍ណែនាំដូចខាងក្រោមពាក់ព័ន្ធនឹងការអនុវត្តវិធាន៨៧ នៃវិធានផ្ទៃក្នុង ត្រង់ផ្នែកដែលវិធាននេះ ជាប់ទាក់ទិននឹងភាពពាក់ព័ន្ធ និងភាពអាចជឿជាក់បាន (រួមទាំងយថាភាព) នៃឯកសារដែលភាគីមានបំណងដាក់នៅចំពោះមុខអង្គជំនុំជម្រះ។

២. វិធាន៨៧(៣)(ក) នៃវិធានផ្ទៃក្នុងតម្រូវថា ឯកសារត្រូវមានភាពជាប់ពាក់ព័ន្ធ។ ឯកសារមួយ ដែលមិនមានភាពជាប់ពាក់ព័ន្ធ ឬគ្មានយថាភាពទេនោះអាចត្រូវបានពិចារណាដោយអង្គជំនុំជម្រះថា "មិនសមស្របសម្រាប់បញ្ជាក់អង្គហេតុដែលជាគោលដៅដែលត្រូវបញ្ជាក់នោះឡើយ" (វិធាន៨៧(៣) (គ) នៃវិធានផ្ទៃក្នុង)។ វិធាន ៨៧(៣) តម្រូវឱ្យឯកសារបំពេញនូវបទដ្ឋាន*នៃសេចក្តីបញ្ជាក់ដំបូង* នៃភាពជាប់ពាក់ព័ន្ធ ភាពអាចជឿជាក់បាន និងយថាភាពនៃឯកសារនោះផង។ ឧទាហរណ៍ ប្រសិនបើឯកសារមួយមិនបានបង្ហាញថា ក្លែងក្លាយ ឬជាឯកសារមិនតំណាងឱ្យឯកសារដើមក្តី ឯកសារនេះនឹងត្រូវបានចាត់ទុកថា បានដាក់នៅចំពោះមុខអង្គជំនុំជម្រះ។ ការជំទាស់ណាមួយលើបញ្ហានេះ ចាំបាច់ត្រូវលើកឡើងនៅពេលដែលឯកសារមួយ ឬ ភស្តុតាងផ្សេង

ទៀតកំពុងត្រូវបានដាក់ចំពោះមុខអង្គជំនុំជម្រះសាលាដំបូង។ សំណើផ្សេងៗអំពីភាពអាចជឿជាក់បាននៃឯកសារ អង្គជំនុំជម្រះនឹងថ្លឹងថ្លែងសម្រេចចំពោះឯកសារនោះ។

៣. វិធាន៦៧(៣) នៃវិធានផ្ទៃក្នុង តម្រូវឲ្យសហចៅក្រមស៊ើបអង្កេតធ្វើការត្រួតពិនិត្យ និងវាយតម្លៃឯកសារទាំងឡាយ ដើម្បីកំណត់ថាតើជាទូទៅ មានភស្តុតាងគ្រប់គ្រាន់ ក្នុងការគាំទ្រដល់បទចោទនានាប្រឆាំងនឹងជនជាប់ចោទដែរ ឬយ៉ាងណា។ ដំណើរការនេះតម្រូវជាចាំបាច់នៅក្នុងដំណាក់កាលស៊ើបអង្កេតឲ្យមានការកំណត់នូវភាពពាក់ព័ន្ធ និងផ្តល់តម្លៃជាភស្តុតាងមួយចំនួនដែលភស្តុតាងទាំងនោះត្រូវបានយោងនៅក្នុងដីកាដំណោះស្រាយ។ បន្ថែមលើនេះទៀត សេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតនេះត្រូវបានពិនិត្យឡើងវិញ នៅពេលមានបណ្តឹងឧទ្ធរណ៍ទៅកាន់អង្គបុរេជំនុំជម្រះ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះសាលាដំបូងធ្វើការសន្មតទៅលើឯកសារនានាក្នុងដីកាដំណោះស្រាយថា មានភាពពាក់ព័ន្ធ និងភាពអាចជឿជាក់បាន រួមទាំងយថាភាពរបស់វាផង ហើយអង្គជំនុំជម្រះបានផ្តល់ចំណាត់ថ្នាក់ E3 ដល់ឯកសារទាំងនោះ។ ពុំមានការសន្មតជាមុនបែបនេះឡើយ ចំពោះឯកសារទាំងឡាយណាដែលមាននៅក្នុងសំណុំរឿង ប៉ុន្តែពុំឃើញមានយោងនៅក្នុងដីកាដំណោះស្រាយនោះ។

៤. ឯកសារដើមគឺជាឯកសារដែលប្រសើរជាងគេសម្រាប់យកមកបង្ហាញជាភស្តុតាង ហើយនឹងត្រូវបានផ្តល់ទម្ងន់ធ្ងន់ជាងឯកសារថតចម្លង។ ការដែលថា ពាក្យពេចន៍ជាក់លាក់នៅក្នុងឯកសារមួយ ពុំអាចអានបាននោះ គឺមិនអាចរារាំងការដាក់ឯកសារនេះ នៅចំពោះមុខអង្គជំនុំជម្រះនោះទេ។ បញ្ហាបែបនេះគឺជាប់ពាក់ព័ន្ធនឹងទម្ងន់នៃភស្តុតាង ហើយនឹងមិនត្រូវបានពិចារណាឡើយ នៅពេលវាយតម្លៃ អំពីលក្ខខណ្ឌតម្រូវនៃវិធាន៨៧(៣) នៃវិធានផ្ទៃក្នុង។

៥. សម្ភារៈមួយចំនួន ដូចជា របាយការណ៍ដែលមានការវិភាគ សៀវភៅ ភាពយន្តឯកសារ និងអត្ថបទដកស្រង់ចេញពីប្រព័ន្ធផ្សព្វផ្សាយអាចមានភាពពាក់ព័ន្ធ ហើយនឹងត្រូវរាប់ចូលជាប្រភេទនៃឯកសារមួយផងដែរ។ ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះនឹងពិចារណាសម្រេចអំពីតម្លៃជាភស្តុតាង នៃឯកសារទាំងនេះ នាពេលសមស្របខាងមុខ។

៦. តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី (ICTY) និងតុលាការព្រហ្មទណ្ឌអន្តរជាតិនានា បានអនុម័តការអនុវត្ត ដែលអនុញ្ញាតឲ្យចៅក្រមដកចេញនូវភស្តុតាង ប្រសិនបើតម្លៃនៃភស្តុតាងនោះ មានលក្ខណៈលម្អៀងជាខ្លាំង ដែលមិនធានាឲ្យមានការជម្រះក្តីប្រកបដោយយុត្តិធម៌។ គោលការណ៍នេះមិនមានចែងក្នុងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ឬ វិធាននៃក្របខ័ណ្ឌច្បាប់ទេ ប៉ុន្តែទោះក្នុងករណីណាក៏ដោយ វាមិនចាំបាច់នោះទេ ពីព្រោះថា ចៅក្រមវិជ្ជាជីវៈមានសមត្ថភាពក្នុងការដកចេញនូវភស្តុតាងទាំងឡាយណាដែលមានលក្ខណៈបុរេវិនិច្ឆ័យដោយមិនត្រឹមត្រូវ។

៧. ពុំមានលក្ខខណ្ឌតម្រូវផ្នែកនីតិវិធីនៅចំពោះមុខ អ.វ.ត.ក ក្នុងការកោះហៅសាក្សីដែលមានចំណេះដឹងផ្ទាល់ខ្លួន យកមកផ្តល់យថាភាពដល់ឯកសារនានានៅក្នុងសំណុំរឿងនោះទេ។ ទោះជាយ៉ាងនេះក្តី សក្ខីកម្មដែលទាក់ទិននឹងដំណើររក្សាទុកភស្តុតាង និងប្រភពនៃឯកសារនឹងជួយដល់អង្គជំនុំជម្រះក្នុងការវាយតម្លៃអំពីទម្ងន់ ដែលត្រូវបញ្ជាក់លើឯកសារជាក់លាក់នានា។

៨. កន្លងមក អង្គជំនុំជម្រះសាលាដំបូង បានបញ្ជាក់ថា ភាគីនានាដែលស្នើសុំបង្ហាញឯកសារនៅពេលសវនាការ ត្រូវធានាឲ្យទាន់ពេលនូវឯកសារបកប្រែជាភាសាផ្លូវការទាំងបីភាសា (E131/1)។ អង្គជំនុំជម្រះសាលាដំបូង នឹងធ្វើការលើកលែងខ្លះ ក្នុងករណីដែលភាគីមិនអាចផ្តល់ឯកសារទាំងបីភាសាបាន ដោយសារអង្គភាពបកប្រែភាសា មានទំហំការងារច្រើនពេកមិនអាចបកប្រែឯកសារបានទាន់ពេលវេលា និងផ្នែកពាក់ព័ន្ធនៃឯកសារដែលភាគីមានបំណងដាក់នៅមុខអង្គជំនុំជម្រះ ត្រូវបានយកទៅប្រើជាមូលដ្ឋានក្នុងការសួរដេញដោលសាក្សី ឬជនជាប់ចោទ ប្រសិនបើឯកសារនោះមានយ៉ាងហោចណាស់មួយភាសា ហើយជាភាសាដែលជនជាប់ចោទ ឬសាក្សី អាចយល់បាន។ លើសពីនេះ ផ្នែកពាក់ព័ន្ធខ្លីៗនៃឯកសារដែលអាចងាយស្រួលក្នុងការបកប្រែនៅក្នុងពេលសវនាការ អង្គជំនុំជម្រះអាចអនុញ្ញាតឲ្យយកផ្នែកពាក់ព័ន្ធខ្លីៗនៃឯកសារនោះមកដាក់ចំពោះមុខជនជាប់ចោទ ឬសាក្សីបាន។

៩. ដោយហេតុថា ភាគីនៅតែបន្តលើកឡើងអំពីបញ្ហានេះ អង្គជំនុំជម្រះសាលាដំបូង សូមបញ្ជាក់ជាថ្មីថា ភស្តុតាងដែលទទួលបានតាមរយៈការធ្វើទារុណកម្ម ត្រូវបានយកមកប្រើប្រាស់ដោយមានកំរិត។ អង្គជំនុំជម្រះសាលាដំបូង សូមរំឭកឡើងវិញនូវអនុស្សរណៈ E74 របស់ខ្លួនក្នុងសំណុំរឿង ០០២ និងសេចក្តីសម្រេចផ្ទាល់មាត់ក្នុងសំណុំរឿង ០០១ នៅថ្ងៃទី ២០ និងថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០០៩។

សេចក្តីសម្រេចផ្ទាល់មាត់នេះ ដោះស្រាយសំណើរបស់ភាគីទាក់ទិនទៅនឹងបទដ្ឋាននៃភាពពាក់ព័ន្ធ ភាពអាចជឿជាក់បាន និងយថាភាព ក្នុងការអនុវត្តវិធាន៨៧ ហើយសេចក្តីសម្រេចផ្ទាល់មាត់នេះ ក៏ជាចម្លើយតបជាផ្លូវការរបស់អង្គជំនុំជម្រះសាលាដំបូងទៅនឹងផ្នែកខ្លះនៃសំណើខាងលើ។ ចំពោះសំណើទាំឡាយណាដែលរួមមាន ការជំទាស់ទៅនឹងឯកសារជាក់លាក់ ឬសំណើផ្សេងៗទៀត ដែលមិនត្រូវបានដោះស្រាយដោយសេចក្តីសម្រេចផ្ទាល់មាត់នេះ នឹងត្រូវដោះស្រាយនាពេលសមស្របខាងមុខ។